# ព្រះរាជក្រម

## យើង

នស/រកម/០៦០៩/០០៩

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការកែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបាន យល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

Downloaded from: http://www.khmerlaws.com

# ច្បាប់

# ស្តីពី

# ការកែតម្រូវនៃច្បាប់ស្តីពី
# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង
# ឆ្នាំ ២០០៩

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

Downloaded from http://www.khmerlaws.com

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់កែតម្រូវនេះ គឺជាច្បាប់ហិរញ្ញវត្ថុបន្ថែមលើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ដែលមានគោលបំណងផ្តល់ហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល សម្រាប់ជួយទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្មនិងកសិ-ឧស្សាហកម្ម ព្រមទាំងផ្តល់ការលើកទឹកចិត្តដល់គម្រោងវិនិយោគ មានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យទាំងពីរនេះ ។

## ជំពូកទី ២
## ប្រភពធនធាន និងការគ្រប់គ្រងមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម

**មាត្រា ២.-**

អនុញ្ញាតឱ្យបង្កើត “មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម” ដែលត្រូវគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មូលនិធិនេះ មានគោលដៅផ្តល់ឥណទានរយៈពេលខ្លី មធ្យម និងវែង សម្រាប់ទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ។

**មាត្រា ៣.-**

ប្រភពធនធាននៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម រួមមាន :

-ហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល តាមរយៈច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ឬ/និង តាមរយៈច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ

Downloaded from http://www.khmerlaws.com

-ការចូលរួមវិភាគទានពីដៃគូអភិវឌ្ឍ និងពីប្រភពផ្សេងៗទៀត ។

**មាត្រា ៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៥.-**

អនុម័តឥណទានពិសេសចំនួន ៧២.០០០.០០០.០០០៛ (ចិតសិបពីរពាន់លានរៀល) បន្ថែមលើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ជាធនធានដំបូង សម្រាប់មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ។ ឥណទានពិសេសនេះមានប្រភពហិរញ្ញប្បទានមកពីប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៣
## ការកំណត់រយៈពេលអាទិភាពសម្រាប់លើកលែងពន្ធលើប្រាក់ចំណេញ ដល់គម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ក្នុងវិស័យកសិកម្មនិងកសិ-ឧស្សាហកម្ម

**មាត្រា ៦.-**

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ត្រូវទទួលបានការលើកទឹកចិត្ត ដោយទទួលបានរយៈពេលអាទិភាពនៃការលើកលែងពន្ធលើប្រាក់ចំណេញចំនួន ៣ (បី)ឆ្នាំ ។ សកម្មភាពវិនិយោគក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

Downloaded from http://www.khmerlaws.com

ដែលទទួលបានការលើកទឹកចិត្តនេះ ត្រូវកំណត់ដោយអនុក្រឹត្យពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីវិនិយោគ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៧.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.–**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០៦០៩.០១១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ ៦២៤ ច.ល

ដើម្បីចម្លងចែកជូន

ភ្នំពេញថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ឃុន ខុនកេន

Downloaded from http://www.khmerlaws.com